ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 12-Jan-2017, 15:14
CMS/CFO: Sann Rada

អង្គជំនុំជម្រះតុលាការកំពូល
Supreme Court Chamber
Chambre de la Cour suprême

សំណុំរឿងលេខៈ ០០២/១៩-កញ្ញា-២០០៧-អ.វ.ត.ក-អ.ជ.ស.ដ/អ.ជ.ត.ក(៣០)
Case File/Dossier N°. 002/19-09-2007-ECCC-TC/SC(30)

**នៅចំពោះមុខ៖**

**ចៅក្រម គង់ ស្រ៊ីម ប្រធាន**
**ចៅក្រម Chandra Nihal JAYASINGHE**
**ចៅក្រម សោម សិរីវឌ្ឍ**
**ចៅក្រម Agniezska KLONOWIECKAMILART**
**ចៅក្រម ម៉ុង មុន្នីចរិយា**
**ចៅក្រម Florence Ndepele Mwachande MUMBA**
**ចៅក្រម យ៉ា ណារិន**

**កាលបរិច្ឆេទឯកសារ៖** ថ្ងៃទី ១២ ខែ មករា ឆ្នាំ ២០១៧
**ភាសាដើម៖** ខ្មែរ/អង់គ្លេស
**ចំណាត់ថ្នាក់ឯកសារ៖** សាធារណៈ

# សេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗរបស់ដើមបណ្តឹងរដ្ឋប្បវេណីជំទាស់សេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងលើវិសាលភាពនៃសំណុំរឿង ០០២ ទាក់ទងការចោទពីបទរំលោភសេពសន្ថវៈ

**សហព្រះរាជអាជ្ញា**

ជា លាង

Nicholas KOUMJIAN

**ជនជាប់ចោទ**

ខៀវ សំផន

នួន ជា

**សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី**

ពេជ អង្គ

Marie GUIRAUD

**សហមេធាវីជនជាប់ចោទ នួន ជា**

សុន អរុណ

Victor KOPPE

**សហមេធាវីជនជាប់ចោទ ខៀវ សំផន**

គង់ សំអុន

Anta GUISSÉ

១. **អង្គជំនុំជម្រះតុលាការកំពូល** នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាសម្រាប់ការកាត់សេចក្តីឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើងក្នុងរយៈកាលកម្ពុជាប្រជាធិបតេយ្យពីចន្លោះថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ ដល់ថ្ងៃទី ០៦ ខែ មករា ឆ្នាំ ១៩៧៩ ("អង្គជំនុំជម្រះតុលាការកំពូល" និង "អ.វ.ត.ក.") បានទទួលបណ្តឹងសាទុក្ខភ្លាមៗរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ចំពោះសំណើសុំការបញ្ជាក់ពីវិសាលភាពទាក់ទងនឹងបទចោទនៃការរំលោភសេពសន្ថវៈនៅក្រៅបរិបទនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ" ដែលបានដាក់នៅថ្ងៃទី ២៨ ខែ កញ្ញា ឆ្នាំ ២០១៦ និងត្រូវបានជូនដំណឹងនៅថ្ងៃទី ១២ ខែ តុលា ឆ្នាំ ២០១៦ ("ម្ចាស់បណ្តឹងសាទុក្ខ" និង"បណ្តឹងសាទុក្ខ")[1]។

## I. សេចក្តីផ្តើម

២. បណ្តឹងសាទុក្ខនេះ ទាក់ទងទៅនឹងសេចក្តីសម្រេចមួយរបស់អង្គជំនុំជម្រះសាលាដំបូងដែលបានចេញនៅថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ២០១៦ ដើម្បីបញ្ជាក់ថា វិសាលភាពនៃការជំនុំជម្រះក្នុងសំណុំរឿង ០០២/០២ ទាក់ទងនឹងបទចោទនៃការរំលោភសេពសន្ថវៈ ពុំរួមបញ្ចូលការចោទប្រកាន់ផ្នែកអង្គហេតុអំពីការរំលោភសេពសន្ថវៈ ពាក់ព័ន្ធទៅនឹងហេតុការណ៍នានាដែលបានកើតឡើងក្រៅបរិបទនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ បើទោះបីជាមានការដាក់បញ្ចូលហេតុការណ៍ទាំងនេះក្នុងដីកាដំណោះស្រាយនៃសំណុំរឿង ០០២[2] ("សេចក្តីសម្រេចរងការជំទាស់")[3]ក៏ដោយ។

### ក. សាវតារ

៣. នៅថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០១០ សហចៅក្រមស៊ើបអង្កេតបានចេញដីកាដំណោះស្រាយក្នុងសំណុំរឿង ០០២។ ក្នុងផ្នែកសម្រេចសេចក្តី ដីកាដំណោះស្រាយបានចោទប្រកាន់ នួន ជា និង ខៀវ សំផន ក្នុងចំណោមមនុស្សដទៃទៀត (ជារួម"ជនជាប់ចោទ") ពីបទរំលោភសេពសន្ថវៈនៅ

---

[1] ឯកសារ E306/7/1/1។

[2] ដីកាដំណោះស្រាយ ចុះថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០១០ និងដាក់នៅថ្ងៃទី ១៦ ខែ កញ្ញា ឆ្នាំ ២០១០ ឯកសារលេខ D427 ("ដីកាដំណោះស្រាយ")។

[3] សេចក្តីសម្រេចលើសារណារបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីអនុលោមតាមវិធាន៩២នៃវិធានផ្ទៃក្នុងស្តីពីការបញ្ជាក់ពីវិសាលភាពនៃសំណុំរឿង ០០២/០២ ទាក់ទិននឹងការចោទប្រកាន់អំពីការរំលោភសេពសន្ថវៈនៅក្រៅបរិបទនៃអាពាហ៍ពិពាហ៍ដោយបង្ខំ ថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ២០១៦ ឯកសារលេខ E306/7/3។

ក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ[4]។ ក្នុងផ្នែកដែលដីកាដំណោះស្រាយលើកឡើងអំពីការយល់ឃើញផ្នែកច្បាប់ទាក់ទងទៅនឹងបទឧក្រិដ្ឋនៃការរំលោភសេពសន្ថវៈ សហចៅក្រមស៊ើបអង្កេតបានយល់ឃើញថា មាន"ការបង្ហាញច្បាស់លាស់"ថា ក្នុងអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យបទរំលោភសេពសន្ថវៈ ត្រូវបានប្រព្រឹត្តឡើងក្នុង"កាលៈទេសៈផ្សេងៗគ្នា" ជាពិសេសនៅតាមមន្ទីរសន្តិសុខ និងសហករណ៍មួយចំនួន ព្រមទាំងក្នុងបរិបទនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ[5]។ ទោះជាយ៉ាងណាក្តី ទាក់ទងនឹងហេតុការណ៍នៃការរំលោភសេពសន្ថវៈដែលត្រូវបានប្រព្រឹត្តឡើងនៅតាមមន្ទីរសន្តិសុខ និងសហករណ៍នានា ដីកាដំណោះស្រាយបានគូសបញ្ជាក់ថា គោលនយោបាយផ្លូវការរបស់បក្សកុម្មុយនីស្តកម្ពុជា ("ប.ក.ក.") គឺដើម្បីទប់ស្កាត់ការកើតឡើងនៃអំពើរំលោភសេពសន្ថវៈ និងផ្តន្ទាទោសចារី។ ហេតុដូច្នេះ "បើទោះបីជាគោលនយោបាយនេះ ពុំអាចទប់ស្កាត់អំពើរំលោភសេពសន្ថវៈបានក៏ដោយ ក៏ពុំអាចត្រូវបានចាត់ទុកថា បទរំលោភសេពសន្ថវៈ គឺស្ថិតក្នុងចំណោមបទឧក្រិដ្ឋនានាដែលមេដឹកនាំ ប.ក.ក. បានប្រើប្រាស់ដើម្បីអនុវត្តគោលបំណងរួមឡើយ។ ប៉ុន្តែ នោះពុំមែនជាករណីនៅក្នុងបរិបទនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ"[6]។ ក្នុងផ្នែកទាក់ទងនឹងការទទួលខុសត្រូវព្រហ្មទណ្ឌរបស់ជនជាប់ចោទ សហចៅក្រមស៊ើបអង្កេតបានពិចារណាឃើញថា ជនជាប់ចោទទទួលខុសត្រូវចំពោះការរំលោភសេពសន្ថវៈក្រោមគោលការណ៍នៃសហឧក្រិដ្ឋកម្មរួម តែក្នុងករណីពាក់ព័ន្ធទៅនឹងគោលនយោបាយនៃ"ការដាក់កំហិតលើការរៀបអាពាហ៍ពិពាហ៍"[7]ប៉ុណ្ណោះ។ ចំណែកទម្រង់នៃការទទួលខុសត្រូវផ្សេងទៀត សហចៅក្រមស៊ើបអង្កេតបានបញ្ជាក់ថា ត្រូវបានបង្ហាញស្របតាមបទដ្ឋានតម្រូវទាក់ទងនឹង"ការរំលោភសេពសន្ថវៈក្នុងបរិបទនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ"[8]។ ជារួម សហចៅក្រមស៊ើបអង្កេតពុំបានពិចារណាឃើញថា ការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌរបស់ជនជាប់ចោទលើការរំលោភសេពសន្ថ

[4] ដីកាដំណោះស្រាយ កថាខណ្ឌ ១៦១៣។

[5] ដីកាដំណោះស្រាយ កថាខណ្ឌ ១៤២៦-១៤៣៣។

[6] ដីកាដំណោះស្រាយ កថាខណ្ឌ ១៤២៩។

[7] ដីកាដំណោះស្រាយ កថាខណ្ឌ ១៥២៥(v)។

[8] ដីកាដំណោះស្រាយ កថាខណ្ឌ ១៥៤៥ (អក្សរ (ឆ) ក្រោមមាតិការឿង "ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ") (ការរៀបចំផែនការ) ១៥៤៨ (អក្សរ (ឆ) ក្រោមមាតិកាវឿង "ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ" (ការញុះញង់), ១៥៥១ (អក្សរ (ឆ) ក្រោមមាតិកាវឿង "ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ") (ការជួយ និងជំរុញ),១៥៥៤ (អក្សរ (ឆ) ក្រោមមាតិកាវឿង "ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ") (ការបញ្ជា), ១៥៥៩ (អក្សរ (ឆ) ក្រោមមាតិកាវឿង "ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ") (ការទទួលខុសត្រូវរបស់ថ្នាក់លើ)។

វៈដែលបានប្រព្រឹត្តនៅតាមមន្ទីរសន្តិសុខ និងសហករណ៍នានាដែលស្ថិតនៅក្រោមបរិបទនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំនោះ ត្រូវបានបង្ហាញស្របតាមបទដ្ឋានតម្រូវក្រោមទម្រង់នៃការទទួលខុសត្រូវណាមួយឡើយ។

៤. នៅថ្ងៃទី ១៣ ខែ មករា ឆ្នាំ ២០១១ ក្នុងការសម្រេចលើបណ្តឹងសាទុក្ខដែលបានធ្វើឡើងប្រឆាំងនឹងដីកាដំណោះស្រាយ អង្គបុរេជំនុំជម្រះបានសម្រេចថា បទរំលោភសេពសន្ថវៈនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ពុំមានអត្ថិភាពក្នុងយុត្តាធិការពេលវេលារបស់ អ.វ.ត.ក. ឡើយ និងបានសម្រេចថា អង្គហេតុមូលដ្ឋាន អាចត្រូវបានចាត់ទុកជាអំពើអមនុស្សធម៌ដទៃទៀតនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ[9]។

៥. នៅថ្ងៃទី ០៤ ខែ មេសា ឆ្នាំ ២០១៤ ក្នុងការចេញសេចក្តីសម្រេចរបស់ខ្លួនស្តីពីការបំបែកកិច្ចដំណើរការនីតិវិធីបន្ថែមដែលសេសសល់ក្នុងសំណុំរឿង ០០២ (“សេចក្តីសម្រេចបំបែកកិច្ចដំណើរការនីតិវិធី”)[10] អង្គជំនុំជម្រះសាលាដំបូងបានសម្រេចដាក់បញ្ចូលក្នុងវិសាលភាពនៃការជំនុំជម្រះក្នុងសំណុំរឿង ០០២/០២ នូវបទចោទនៃ“ការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ និងការរំលោភសេពសន្ថវៈនៅទូទាំងប្រទេស”[11]។ ក្នុងឧបសម្ព័ន្ធមួយដែលជាផ្នែកមួយនៃដីកាបំបែកកិច្ចដំណើរការនីតិវិធីនេះ (“ឧបសម្ព័ន្ធនៃដីកាបំបែកកិច្ចដំណើរការនីតិវិធី”)[12] អង្គជំនុំជម្រះសាលាដំបូងបានបញ្ជាក់អំពីបញ្ជីកថាខណ្ឌ និងផ្នែកនានានៃដីកាដំណោះស្រាយដែលពាក់ព័ន្ធសំណុំរឿង ០០២/០២ ហើយអង្គជំនុំជម្រះសាលាដំបូងបានដាក់បញ្ចូលទៅក្នុងបញ្ជីនោះនូវកថាខណ្ឌទាំងប៉ុន្មាន ដែលយោងទៅលើផ្នែកនានានៃដីកាដំណោះស្រាយដែលមានចំណងជើងថា “ការរំលោភសេពសន្ថវៈនៅតាមមន្ទីរសន្តិសុខ និងសហករណ៍នានា” និង“ការរំលោភសេពសន្ថវៈក្នុងបរិបទនៃការរៀបអាពាហ៍ពិពាហ៍

[9] *សូមមើលឧទាហរណ៍* សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធ និង នួន ជា ប្រឆាំងនឹងដីកាដំណោះស្រាយ ថ្ងៃទី ១៣ ខែ មករា ឆ្នាំ ២០១១ ឯកសារលេខ D427/2/12 កថាខណ្ឌ ១១(២) នៃផ្នែកសម្រេចសេចក្តី។ សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ ខៀវ សំផន ប្រឆាំងនឹងដីកាដំណោះស្រាយ ថ្ងៃទី ២១ ខែ មករា ឆ្នាំ ២០១១ ឯកសារ D427/4/15 កថាខណ្ឌ ២(២)(២)។

[10] សេចក្តីសម្រេចលើការបំបែកកិច្ចដំណើរការនីតិវិធីបន្ថែមលើសំណុំរឿង ០០២ និងវិសាលភាពនៃសំណុំរឿង ០០២/០២ ថ្ងៃទី ៤ ខែ មេសា ឆ្នាំ ២០១៤ ឯកសារលេខ E301/9/1។

[11] សេចក្តីសម្រេចបំបែកកិច្ចនីតិវិធី កថាខណ្ឌ ៣៣ និងកថាខណ្ឌអនុភាពទីបី។

[12] ឧបសម្ព័ន្ធ៖ បញ្ជីកថាខណ្ឌ និងផ្នែកនានានៃដីកាដំណោះស្រាយដែលពាក់ព័ន្ធសំណុំរឿង០០២/០២ ថ្ងៃទី ៤ ខែ មេសា ឆ្នាំ ២០១៤ ឯកសារលេខ E301/9/1.1។

ដោយបង្ខំ"[13]។

៦. នៅថ្ងៃទី ២៥ ខែ មេសា ឆ្នាំ ២០១៤ ក្នុងសេចក្តីសម្រេចស្តីពីអញ្ញត្រកម្មរបស់ខ្លួន[14] អង្គជំនុំជម្រះសាលាដំបូងបានបញ្ជាក់អះអាងថា "គ្មានមូលដ្ឋានផ្លូវច្បាប់សម្រាប់សំណើរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីសុំដាក់បន្ថែមបទចោទនៃការរំលោភសេពសន្ថវៈ (ក្រៅបរិបទនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ) ដែលត្រូវបានប្រព្រឹត្តនៅតាមមន្ទីរសន្តិសុខ ពីលើដីកាដំណោះស្រាយឡើយនោះឡើយ"[15]។ ដូចមានចែងក្នុងវិធាន ៩៨(២) នៃវិធានផ្ទៃក្នុង[16] អង្គជំនុំជម្រះសាលាដំបូង"មិនអាចបញ្ចូលនូវធាតុផ្សំថ្មីនៃបទចោទ ឬអង្គហេតុទៅលើដីកាដំណោះស្រាយដែលត្រូវបានច្រានចោលដោយសហចៅក្រមស៊ើបអង្កេតឡើយ ដែលជាសេចក្តីសម្រេចមួយដែលអង្គបុរេជំនុំជម្រះត្រូវទទួលយកជាការបាន"[17]។

៧. នៅថ្ងៃទី ១២ ខែ មិថុនា ឆ្នាំ ២០១៥ អង្គជំនុំជម្រះសាលាដំបូងបានគូសបញ្ជាក់ថា ទោះជាសហចៅក្រមស៊ើបអង្កេតបានសម្រេចថា ហេតុការណ៍នៃរំលោភសេពសន្ថវៈត្រូវបានប្រព្រឹត្តឡើងក្នុងចំណោមទីតាំងផ្សេងៗនៅមន្ទីរសន្តិសុខក្រាំងតាចាន់ក៏ដោយ ក៏សហចៅក្រមស៊ើបអង្កេតពុំបានដាក់ហេតុការណ៍ទាំងនោះឱ្យជនជាប់ចោទទទួលខុសត្រូវ តាមរយៈទម្រង់នៃការទទួលខុសត្រូវណាមួយឡើយ[18]។ ទាក់ទងទៅនឹងបញ្ហានេះ អង្គជំនុំជម្រះសាលាដំបូងបានរំលឹកថា សំណើរបស់ម្ចាស់បណ្តឹងសាទុក្ខ"សុំបន្ថែមបទចោទនៃការរំលោភសេពសន្ថវៈ" ត្រូវបានបដិសេធចោលនៅក្នុងសេចក្តីសម្រេចស្តីពីអញ្ញត្រកម្ម[19]។ ប៉ុន្តែ អង្គជំនុំជម្រះសាលាដំបូងបានបន្ថែមថា "ការកើតមានការ

---

[13] ឧបសម្ព័ន្ធនៃសេចក្តីសម្រេចបំបែកកិច្ចនីតិវិធី ទំព័រ៤ ផ្នែក៥(ii)(ខ)(១០) ដោយយោងលើដីកាដំណោះស្រាយ កថាខណ្ឌ ១៤២៦ ដល់ ១៤៣៣។

[14] អនុស្សរណៈអង្គជំនុំជម្រះសាលាដំបូងដែលមានចំណងជើង "ព័ត៌មានបន្ថែមទាក់ទងនឹងអញ្ញត្រកម្មដែលនៅសេសសល់" ថ្ងៃទី ២៥ ខែ មេសា ឆ្នាំ ២០១៤ ឯកសារ E306 ("សេចក្តីសម្រេចស្តីពីអញ្ញត្រកម្ម")។

[15] សេចក្តីសម្រេចស្តីពីអញ្ញត្រកម្ម កថាខណ្ឌ ៣។

[16] វិធានផ្ទៃក្នុង អ.វ.ត.ក វិសោធនកម្មលើកទី ៩ ថ្ងៃទី ១៦ ខែ មករា ឆ្នាំ ២០១៥ ("វិធានផ្ទៃក្នុង")។

[17] សេចក្តីសម្រេចស្តីពីអញ្ញត្រកម្ម កថាខណ្ឌ ៣។

[18] សេចក្តីសម្រេចលើសំណើរបស់ ខៀវ សំផន សុំឱ្យមានការតទល់គ្នារវាងដើមបណ្តឹងរដ្ឋប្បវេណី សយ សែន ជាមួយនឹងសាក្សី ស្រី ចន និងដើមបណ្តឹងរដ្ឋប្បវេណី សូត្រ សាំង និងស្នើសុំឯកសារថតចម្លងនៃការស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី សយ សែន ថ្ងៃទី ១២ ខែ មិថុនា ឆ្នាំ ២០១៥ ឯកសារលេខ E348/4 កថាខណ្ឌ ១១ (សេចក្តីសម្រេចស្តីពីការសួរសំណួរសាក្សី)។

[19] សេចក្តីសម្រេចលើការតទល់សាក្សី កថាខណ្ឌ ១១ ដោយយោងសេចក្តីសម្រេចស្តីពីអញ្ញត្រកម្ម កថាខណ្ឌ ៣។

វិលោភសេពសន្ថវៈអាចពាក់ព័ន្ធ ក្នុងចំណោមនោះ ទៅនឹងលក្ខខណ្ឌនៅមន្ទីរសន្តិសុខក្រាំងតាចាន់"[20]។

៨. នៅថ្ងៃទី ១៨ ខែ មីនា ឆ្នាំ ២០១៦ ម្ចាស់បណ្តឹងសាទុក្ខបានដាក់សំណើ *ក្នុងចំណោមនោះ* សុំឱ្យអង្គជំនុំជម្រះសាលាដំបូងបញ្ជាក់ថា ខ្លួន"ទទួលយកជាផ្លូវការនូវការចោទប្រកាន់ផ្នែកអង្គហេតុអំពីការវិលោភសេពសន្ថវៈ" ទាក់ទងទៅនឹងហេតុការណ៍ដែលបានកើតឡើងនៅក្រោបរិបទនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ("សំណើសុំការបញ្ជាក់")[21]។

៩. នៅថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ២០១៦ អង្គជំនុំជម្រះសាលាដំបូងបានចេញសេចក្តីសម្រេចរងការជំទាស់នេះ។

១០. នៅថ្ងៃទី ២៨ ខែ កញ្ញា ឆ្នាំ ២០១៦ ម្ចាស់បណ្តឹងសាទុក្ខបានដាក់បណ្តឹងសាទុក្ខរបស់ខ្លួននៅចំពោះមុខអង្គជំនុំជម្រះតុលាការកំពូល។ នៅថ្ងៃទី ១១ ខែ តុលា ឆ្នាំ ២០១៦ ក្រឡាបញ្ជីនៃអង្គជំនុំជម្រះតុលាការកំពូលបានកត់សម្គាល់ឃើញថា មានកំហុសនីតិវិធីក្នុងការដាក់បណ្តឹងសាទុក្ខនេះ ដោយហេតុថា វិធាន ១០៦(២) នៃវិធានផ្ទៃក្នុងចែងថា "បណ្តឹងសាទុក្ខភ្លាមៗត្រូវដាក់នៅក្រឡាបញ្ជីនៃអង្គជំនុំជម្រះសាលាដំបូង"។ ក្រឡាបញ្ជីនៃអង្គជំនុំជម្រះតុលាការកំពូលបានណែនាំមន្ត្រីទទួលបន្ទុកសំណុំរឿងឱ្យបញ្ជូនបណ្តឹងសាទុក្ខនេះទៅអង្គជំនុំជម្រះសាលាដំបូង ដែលបានជូនដំណឹងដល់ភាគីទាំងអស់ក្នុងសំណុំរឿង ០០២ នៅថ្ងៃទី ១២ ខែ តុលា ឆ្នាំ ២០១៦។

១១. នៅថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ២០១៦ ខៀវ សំផន បានដាក់សារណាតបទៅនឹងបណ្តឹងសាទុក្ខនេះ ("សារណាតបរបស់ ខៀវ សំផន")[22]។

---

[20] សេចក្តីសម្រេចលើការតទល់សាក្សី កថាខណ្ឌ ១១។

[21] សារណារបស់សហមេធាវីនាំមុខដើមបណ្តឹងរដ្ឋប្បវេណីអនុលោមតាមវិធាន៩២នៃវិធានផ្ទៃក្នុងស្តីពីការបញ្ជាក់ពីវិសាលភាពនៃសំណុំរឿង ០០២/០២ ទាក់ទងនឹងបទចោទនៃការវិលោភសេពសន្ថវៈនៅក្រោបរិបទនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ ថ្ងៃទី ១៨ ខែ មីនា ឆ្នាំ ២០១៦ ឯកសារ E306/7 កថាខណ្ឌ ២៨(ក)។

[22] ចម្លើយតបរបស់មេធាវីការពារក្តី លោក ខៀវ សំផន នៅនឹងបណ្តឹងសាទុក្ខភ្លាមៗរបស់ដើមបណ្តឹងរដ្ឋប្បវេណី ពាក់ព័ន្ធនឹងអំពើវិលោភសេពសន្ថវៈក្រៅអាពាហ៍ពិពាហ៍ ថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ២០១៦ ឯកសារ E306/7/3/1/2។

១២. នៅថ្ងៃដដែល បន្ទាប់ពីទទួលបានការអនុញ្ញាតពីអង្គជំនុំជម្រះតុលាការកំពូល[23] សហព្រះរាជអាជ្ញាបានដាក់សារណាតបរបស់ខ្លួនជាភាសាអង់គ្លេសប៉ុណ្ណោះ ឯកសារបកប្រែជាភាសាខ្មែរបានដាក់នៅថ្ងៃទី ២៧ ខែ តុលា ឆ្នាំ ២០១៦ ("សារណាតបរបស់សហព្រះរាជអាជ្ញា")[24]។

ខ. សេចក្តីសម្រេចរងការជំទាស់

១៣. តាមរយៈសេចក្តីសម្រេចរងការជំទាស់នេះ អង្គជំនុំជម្រះសាលាដំបូងបានបដិសេធសំណើសុំកែប្រែប្រភេទបទល្មើសលើការចោទប្រកាន់ផ្នែកអង្គហេតុនៃការរំលោភសេពសន្ថវៈ" ដែលបានកើតឡើងនៅតាមទីតាំងមួយចំនួន និងនៅក្រៅបរិបទនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ[25]។ ដោយយោងទៅលើដីកាដំណោះស្រាយដែលបានធ្វើការកែប្រែដោយអង្គបុរេជំនុំជម្រះ សេចក្តីសម្រេចបំបែកកិច្ចដំណើរការនីតិវិធី សេចក្តីសម្រេចស្តីពីអញ្ញត្រកម្ម និងសេចក្តីសម្រេចស្តីពីការតទល់របស់សាក្សី អង្គជំនុំជម្រះសាលាដំបូងបានផ្តល់សំអាងហេតុថា ការស្របតាមសំណើរបស់ដើមបណ្តឹងរដ្ឋប្បវេណី"នឹងមានអានុភាពបន្ថែមបទចោទថ្មីៗ ឬដាក់បន្ថែមទម្រង់នៃការទទួលខុសត្រូវថ្មីៗលើជនជាប់ចោទ ចំពោះការចោទប្រកាន់ផ្នែកអង្គហេតុដែលពុំត្រូវបានចោទជាផ្លូវការនៅក្នុងដីកាដំណោះស្រាយ" ដែលនេះជាការរំលោភលើវិធាន ៩៨(២)នៃវិធានផ្ទៃក្នុង[26]។ នេះដោយសារអង្គជំនុំជម្រះសាលាដំបូងយល់ឃើញថា ការពិនិត្យជារួមលើដីកាដំណោះស្រាយបង្ហាញថា ករណីនៃការរំលោភសេពសន្ថវៈដែលបានកើតឡើងនៅក្រៅបរិបទនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ ពុំមានអត្ថិភាពនៅក្នុងអង្គហេតុ ដែលជាមូលដ្ឋាននៃបទឧក្រិដ្ឋដែលជនជាប់ចោទត្រូវបានចោទប្រកាន់ជាផ្លូវការនោះឡើយ[27]។ ជាចុងក្រោយ អង្គជំនុំជម្រះសាលាដំបូងបានបញ្ជាក់ថា សេចក្តីសម្រេចដែលរងការជំទាស់នេះពុំបានសម្រេចលើសំណើសុំឲ្យពិចារណាឡើងវិញអំពីការសម្រេចពីដំបូងរបស់ខ្លួនស្តីពី

---

[23] សារអេឡិចត្រូនិកផ្ញើពីក្រឡាបញ្ជីអង្គជំនុំជម្រះតុលាការកំពូលទៅមន្ត្រីគ្រប់គ្រងសំណុំរឿងដែលមានចំណងជើង "សំណើសុំដាក់ចម្លើយតបទៅនឹងបណ្តឹងសាទុក្ខឆ្លាមៗរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីទាក់ទងអំពើរំលោភសេពសន្ថវៈក្រៅអាពាហ៍ពិពាហ៍ដោយបង្ខំជាមួយភាសា" ថ្ងៃទី ១៩ ខែ តុលា ឆ្នាំ ២០១៦ ម៉ោង ២៖១៣ នាទីរសៀល។

[24] ចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹងបណ្តឹងសាទុក្ខឆ្លាមៗរបស់សហមេធាវី នាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងទាក់ទងនឹង ការរំលោភសេពសន្ថវៈនៅក្រៅបរិបទនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ ថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ២០១៦ ឯកសារ E306/7/3/1/3។

[25] សេចក្តីសម្រេចដែលរងការជំទាស់ ផ្នែកសម្រេចសេចក្តី។

[26] សេចក្តីសម្រេចដែលរងការជំទាស់ កថាខណ្ឌ ១៩។

[27] សេចក្តីសម្រេចដែលរងការជំទាស់ កថាខណ្ឌ ១២-១៥។

01376084


បញ្ហានេះឡើយ ប៉ុន្តែ"បានត្រឹមតែផ្តល់ការបញ្ជាក់បំភ្លឺអំពីវិសាលភាពបទចោទនៃការរំលោភសេពសន្ថវៈ ប្រឆាំងនឹងជនជាប់ចោទក្នុងសំណុំរឿង ០០២/០២ ប៉ុណ្ណោះ"[28]។

គ. បណ្តឹងសាទុក្ខ

១៤. ម្ចាស់បណ្តឹងសាទុក្ខបានលើកឡើងថា បណ្តឹងសាទុក្ខនេះអាចទទួលយកបាន និងថា សេចក្តីសម្រេចដែលរងការជំទាស់នេះ មានកំហុសអង្គច្បាប់ និងកំហុសជាក់ស្តែងឱ្យឃើញចេញពីការអនុវត្តឆន្ទានុសិទ្ធិរបស់អង្គជំនុំជម្រះសាលាដំបូង ដែលបានបង្កព្យសនកម្មដល់ដើមបណ្តឹងរដ្ឋប្បវេណី ដែលកំហុសនីមួយៗធ្វើឱ្យសេចក្តីសម្រេចដែលរងការជំទាស់អស់សុពលភាព[29]។ ម្ចាស់បណ្តឹងសាទុក្ខបានអះអាងថា អង្គជំនុំជម្រះសាលាដំបូងយល់ពុំត្រឹមត្រូវលើសំណើសុំការបញ្ជាក់ដែលនេះពុំមែនជាការស្នើសុំកែប្រែប្រភេទបទល្មើសលើការចោទប្រកាន់ផ្នែកអង្គហេតុនៃការរំលោភសេពសន្ថវៈនោះទេ ប៉ុន្តែជាការស្នើសុំការបញ្ជាក់អះអាងថា ការចោទប្រកាន់ទាំងនោះស្ថិត(រួចហើយ)ក្នុងវិសាលភាពនៃសំណុំរឿង ០០២/០២ ដែលជាកំហុសក្នុងការទុកចោលមិនដោះស្រាយ[30]។ ជាសំខាន់ ម្ចាស់បណ្តឹងសាទុក្ខបានអះអាងថា ពាក្យពេចន៍ដែលប្រើក្នុងដីកាដំណោះស្រាយពុំបានតម្រូវឱ្យមានការសន្និដ្ឋានថា សហចៅក្រមស៊ើបអង្កេតបានច្រានចោលការចោទប្រកាន់ផ្នែកអង្គហេតុនៃការរំលោភសេពសន្ថវៈ ដែលពុំស្ថិតក្នុងបរិបទនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំឡើយ ប៉ុន្តែ ផ្អែកតាមការបញ្ជូនដីកាដំណោះស្រាយ អង្គជំនុំជម្រះសាលាដំបូងទទួលយកជាស្វ័យប្រវត្តិនូវការចោទប្រកាន់ផ្នែកអង្គហេតុទាំងនោះ[31]។ ហេតុដូច្នេះ អង្គជំនុំជម្រះមានសិទ្ធិក្នុងការធ្វើសេចក្តីសន្និដ្ឋានមួយផ្សេង ទាក់ទងទៅនឹងលទ្ធភាពនៃការដាក់ឱ្យជនជាប់ចោទទទួលខុសត្រូវអំពីការចោទប្រកាន់ផ្នែកអង្គហេតុនៃការរំលោភសេពសន្ថវៈ ដោយផ្អែកលើភស្តុតាងនៅចំពោះមុខខ្លួននៅពេលបញ្ចប់ការជំនុំជម្រះ[32]។

១៥. ក្នុងសារណាតប ខៀវ សំផន បានស្នើសុំឱ្យអង្គជំនុំជម្រះតុលាការកំពូលប្រកាសថា បណ្តឹងសាទុក្ខនេះមិនអាចទទួលយកបាន ដោយហេតុថា សេចក្តីសម្រេចដែលរងការជំទាស់គ្មានអានុភាពបញ្ចប់

[28] សេចក្តីសម្រេចដែលរងការជំទាស់ កថាខណ្ឌ ២០។

[29] បណ្តឹងសាទុក្ខ កថាខណ្ឌ ២, ៤៩, ៩២។

[30] បណ្តឹងសាទុក្ខ កថាខណ្ឌ ៦២, ៦៥, ៧៣-៧៥។

[31] បណ្តឹងសាទុក្ខ កថាខណ្ឌ ៥៤-៥៩, ៧៨, ៨៣។

[32] បណ្តឹងសាទុក្ខ កថាខណ្ឌ ៣៣-៣៥, ៥៦, ៥៨, ៧៨, ៨១, ៩០។

កិច្ចដំណើរការនីតិវិធីទាក់ទងនឹងបទចោទនៃការរំលោភសេពសន្ថវៈ ដែលនៅក្រៅបរិបទនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ[33]។ ស្រដៀងគ្នានេះ សហព្រះរាជអាជ្ញាបានលើកឡើងថា បណ្តឹងសាទុក្ខនេះមិនអាចទទួលយកបាន ដោយសារយឺតពេល និងគ្មានមូលដ្ឋានគាំទ្រ[34]។

## II. បទដ្ឋាននៃការពិនិត្យឡើងវិញ

១៦. អនុលោមតាមវិធាន ១០៤(៤) នៃវិធានផ្ទៃក្នុង មានតែសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងដូចខាងក្រោមប៉ុណ្ណោះ ដែលបើកផ្លូវឲ្យប្តឹងសាទុក្ខភ្លាមៗ៖ (ក) សេចក្តីសម្រេចដែលមានអានុភាពបញ្ចប់កិច្ចដំណើរការនីតិវិធី (ខ) សេចក្តីសម្រេចស្តីពីការឃុំខ្លួន និងការដាក់ឲ្យស្ថិតក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការអនុលោមតាមវិធាន ៨២ នៃវិធានផ្ទៃក្នុង (គ) សេចក្តីសម្រេចស្តីពីវិធានការការពារតាមវិធាន ២៩(៤-គ) នៃវិធានផ្ទៃក្នុង និង (ឃ) សេចក្តីសម្រេចស្តីពីការជ្រៀតជ្រែកចូលក្នុងកិច្ចការរដ្ឋបាលតុលាការ តាមវិធាន ៣៥(៦) នៃវិធានផ្ទៃក្នុង។ សេចក្តីសម្រេចផ្សេងទៀតអាចប្តឹងសាទុក្ខបានតែក្នុងករណី ដែលបានធ្វើឡើងស្របពេលជាមួយបណ្តឹងសាទុក្ខប្រឆាំងនឹងសាលក្រមលើអង្គសេចក្តី។

១៧. អនុលោមតាមវិធាន ១០៤(១) និង ១០៥(៤) នៃវិធានផ្ទៃក្នុង អង្គជំនុំជម្រះតុលាការកំពូលត្រូវសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗដោយផ្អែកលើមូលដ្ឋានដូចខាងក្រោម៖ (ក) កំហុសអង្គច្បាប់ដែលនាំឲ្យមោឃៈសេចក្តីសម្រេចនោះ (ខ) កំហុសអង្គហេតុដែលនាំឲ្យសេចក្តីសម្រេចនោះមានភាពមិនយុត្តិធម៌ ឬ (គ) ការភ័ន្តច្រឡំដែលស្តែងចេញពីការប្រើប្រាស់ឆន្ទានុសិទ្ធិរបស់អង្គជំនុំជម្រះសាលាដំបូងដែលនាំឲ្យប៉ះពាល់សិទ្ធិរបស់ម្ចាស់បណ្តឹងសាទុក្ខ។

## III. ភាពអាចទទួលយកបាន

### ក. សារណា

១៨. ម្ចាស់បណ្តឹងសាទុក្ខបានអះអាងថា បណ្តឹងសាទុក្ខរបស់ខ្លួនស្របតាមវិធាន ១០៤(៤-ក) នៃវិធានផ្ទៃក្នុង និងបានអះអាងថា សេចក្តីសម្រេចដែលរងការជំទាស់នេះ មានអានុភាពបញ្ចប់កិច្ចដំណើរការនីតិវិធីទាក់ទងនឹងការចោទប្រកាន់ផ្អែកអង្គហេតុនៃការរំលោភសេពសន្ថវៈ ដែលនៅក្រៅបរិបទ

[33] ចម្លើយតបរបស់ ខៀវ សំផន កថាខណ្ឌ ៤០-៤១។

[34] ចម្លើយតបរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ១៩, ៤១។

នៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ ដែលអង្គជំនុំជម្រះសាលាដំបូងបានទទួលយកបន្ទាប់ពីការចេញដីកាដំណោះស្រាយ[35]។ ម្ចាស់បណ្តឹងសាទុក្ខបានអះអាងបន្ថែមទៀតថា សិទ្ធិរបស់ដើមបណ្តឹងរដ្ឋប្បវេណីក្នុងការធ្វើបណ្តឹងសាទុក្ខប្រឆាំងនឹងសេចក្តីសម្រេចដែលរងការជំទាស់នេះ ចេញមកពីសិទ្ធិរបស់ខ្លួនជាភាគីនៅក្នុងកិច្ចដំណើរការនីតិវិធីបច្ចុប្បន្ន ដោយហេតុថា វិធាន ១០៥(២) នៃវិធានផ្ទៃក្នុងបានអនុញ្ញាតឲ្យ“ភាគី”ធ្វើបណ្តឹងសាទុក្ខភ្លាមៗ ហើយសិទ្ធិនេះមិនមែនតែសម្រាប់ភាគីណាមួយជាក់លាក់នោះឡើយ គឺ“អព្យាក្រឹត” ហើយដើមបណ្តឹងរដ្ឋប្បវេណីមានអត្ថប្រយោជន៍ផ្លូវច្បាប់ក្នុងការជំទាស់នឹងសេចក្តីសម្រេចនេះ[36]។ ម្ចាស់បណ្តឹងសាទុក្ខបានអះអាងថា សេចក្តីសម្រេចស្តីពីអញ្ញត្រកម្មបានដោះស្រាយសំណើរបស់ខ្លួន ដែលសុំឲ្យកែប្រែប្រភេទបទល្មើសចំពោះអង្គហេតុនៃការរំលោភសេពសន្ថវៈ ឲ្យទៅជាបទឧក្រិដ្ឋមួយដាច់ដោយឡែកនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិក្តុង ដែលនេះជាបញ្ហាមួយខុសប្លែកពីបញ្ហាទាក់ទងទៅនឹង*វិសាលភាពនៃសំណុំរឿង*របស់អង្គជំនុំជម្រះសាលាដំបូងក្នុងសំណុំរឿង ០០២/០២[37]។ ម្ចាស់បណ្តឹងសាទុក្ខអះអាងថា សំណើសុំការបញ្ជាក់បំភ្លឺ ព្រមទាំងបណ្តឹងសាទុក្ខនេះ គឺសុំដំណោះស្រាយតែទៅលើបញ្ហាគតិយុត្តប៉ុណ្ណោះ[38]។

១៩. ខៀវ សំផន បានអះអាងថា បណ្តឹងសាទុក្ខនេះ ពុំអាចទទួលយកបាន ដោយហេតុថា សេចក្តីសម្រេចដែលរងការជំទាស់នេះ ពុំបាននាំទៅដល់ការបញ្ចប់កិច្ចដំណើរការនីតិវិធី។ ដោយហេតុថា ដីកាដំណោះស្រាយពុំបានចោទប្រកាន់ជនជាប់ចោទពីបទរំលោភសេពសន្ថវៈ ដែលត្រូវបានប្រព្រឹត្តនៅក្រៅបរិបទនៃការរៀបអាពាហ៍ពិពាហ៍ ដែលជាសេចក្តីសម្រេចមួយពុំត្រូវបានជំទាស់នៅចំពោះមុខអង្គបុរេជំនុំជម្រះនោះ បានក្លាយជា*អាជ្ញាអស់ជំនុំ*[39] ហើយអង្គជំនុំជម្រះសាលាដំបូងពុំដែលទទួលយកករណីនេះ និងពុំអាចបញ្ចប់កិច្ចដំណើរការនីតិវិធីពាក់ព័ន្ធណាមួយដែលពុំទាន់បានសម្រេចនៅចំពោះមុខអង្គជំនុំជម្រះឡើយ[40]។ ខៀវ សំផន បានកត់សម្គាល់បន្ថែមទៀតថា ក្នុងឆ្នាំ ២០១១ ម្ចាស់បណ្តឹងសាទុក្ខបានទទួលស្គាល់ដោយភ័ន្តច្រឡំថា សហចៅក្រមស៊ើបអង្កេតពុំបាន

---

[35] បណ្តឹងសាទុក្ខ កថាខណ្ឌ ៥០-៦៦, ៧៨។

[36] បណ្តឹងសាទុក្ខ កថាខណ្ឌ ៤៣, ៤៥, ៥០, ៦៧-៧២។

[37] បណ្តឹងសាទុក្ខ កថាខណ្ឌ ១១, ១៣, ៦១, ៧៥។

[38] បណ្តឹងសាទុក្ខ កថាខណ្ឌ ៧៥, ៩៤។

[39] ចម្លើយតបរបស់ ខៀវ សំផន កថាខណ្ឌ ២០, ២៥។

[40] ចម្លើយតបរបស់ ខៀវ សំផន កថាខណ្ឌ ១៤។

ចោទប្រកាន់ជនជាប់ចោទអំពីការចោទប្រកាន់ខាងលើឡើយ[41]។

២០. សហព្រះរាជអាជ្ញាបានឆ្លើយតបថា បណ្តឹងសាទុក្ខនេះ ពុំអាចទទួលយកបាន ដោយផ្អែកលើមូលដ្ឋានចំនួនពីរដូចតទៅៈ (i) អង្គជំនុំជម្រះសាលាដំបូងពុំដែលទទួលយកការចោទប្រកាន់ផ្នែកអង្គហេតុទាំងនោះឡើយ ហេតុដូច្នេះ សេចក្តីសម្រេចដែលរងការជំទាស់ គ្មានអានុភាពបញ្ចប់កិច្ចដំណើរការនីតិវិធីឡើយ[42] (ii) ដោយហេតុថា អង្គជំនុំជម្រះសាលាដំបូងបានសម្រេចពីរដងរួចមក ហើយលើបញ្ហាដដែលនេះ បណ្តឹងសាទុក្ខនេះ ដាក់យឺតពេល អនុលោមតាមវិធាន ១០៧(១) នៃវិធានផ្ទៃក្នុង[43]។

២១. អង្គជំនុំជម្រះតុលាការកំពូលនឹងធ្វើការដោះស្រាយលើអំណះអំណាងទាំងនេះតាមលំដាប់លំដោយ។

## ខ. ការពិភាក្សា

២២. ភាពអាចទទួលយកបាននៃបណ្តឹងសាទុក្ខនេះ អាស្រ័យលើបញ្ហាគតិយុត្តបីផ្សេងគ្នា គឺ (i) ថាតើសេចក្តីសម្រេចដែលរងការជំទាស់នោះ បានមានអានុភាពបញ្ចប់កិច្ចដំណើរការនីតិវិធីស្របតាមអត្ថន័យនៃវិធាន ១០៤(៤-ក) នៃវិធានផ្ទៃក្នុង ដែរ ឬយ៉ាងណា (ii) ថាតើបណ្តឹងសាទុក្ខនេះ ធ្វើឡើងទាន់ពេល អនុលោមតាមវិធាន ១០៧(១) ដែរ ឬយ៉ាងណា និង (iii) ថាតើដើមបណ្តឹងរដ្ឋប្បវេណី មាន*សិទ្ធិ*ធ្វើបណ្តឹងសាទុក្ខភ្លាមៗប្រឆាំងនឹងសេចក្តីសម្រេចដែលរងការជំទាស់នេះ អនុលោមតាមវិធាន ១០៤(៤-ក) នៃវិធានផ្ទៃក្នុង ដែរ ឬយ៉ាងណា។

២៣. ទាក់ទងទៅនឹងបញ្ហាទីមួយ អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ឃើញថា ការសម្រេចរបស់ខ្លួនជាប់ពាក់ព័ន្ធយ៉ាងខ្លាំងទៅនឹងអង្គសេចក្តីនៃបណ្តឹងសាទុក្ខត្រង់ចំណុចដែលថា ការយល់ឃើញដែលថា សេចក្តីសម្រេចរងការជំទាស់នេះ មាន ឬគ្មានអានុភាពបញ្ចប់កិច្ចដំណើរការនីតិវិធី

---

[41] ចម្លើយតបរបស់ ខៀវ សំផន កថាខណ្ឌ ៦, ដោយដកស្រង់ចម្លើយតបរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីទៅនឹងសំណើរបស់សហព្រះរាជអាជ្ញាសុំកំណត់បទចោទជាថ្មីលើអង្គហេតុដែលបញ្ជាក់អំពីអំពើរំលោភសេពសន្ថវៈជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ, ថ្ងៃទី ២២ ខែ កក្កដា ឆ្នាំ ២០១១ ឯកសារ E99/1 ("សារណា២០១១របស់ដើមបណ្តឹងរដ្ឋប្បវេណី") កថាខណ្ឌ ៣២,៤០។ *សូមមើលផងដែរ* ចម្លើយតបរបស់ ខៀវ សំផន កថាខណ្ឌ ២៩។

[42] ចម្លើយតបរបស់ ខៀវ សំផន កថាខណ្ឌ ១៧។

[43] ចម្លើយតបរបស់ ខៀវ សំផន កថាខណ្ឌ ៣(ខ), ៧, ១១។

សម្រាប់គោលបំណងនៃវិធាន ១០៤(៤-ក) នៃវិធានផ្ទៃក្នុង អាចឆ្លើយទៅនឹងចំណុចសំខាន់ដែលស្ថិតក្នុងការវិវាទនាពេលបច្ចុប្បន្ននេះ គឺថាតើ អង្គជំនុំជម្រះសាលាដំបូងបានទទួលយកការចោទប្រកាន់ផ្នែកអង្គហេតុនៃការរំលោភសេពសន្ថវៈ ដែលបានកើតឡើងនៅក្រៅបរិបទនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ ដែរ ឬយ៉ាងណា។ ហេតុដូច្នេះ អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា ជាការសមស្របក្នុងការភ្ជាប់បញ្ហានេះជាមួយនឹងអង្គសេចក្ដីនៃបណ្ដឹងសាទុក្ខនេះ ដើម្បីឱ្យបញ្ហានេះត្រូវបានសម្រេចតែនៅក្នុងករណី ដែលបណ្ដឹងសាទុក្ខត្រូវបានប្រកាសថា អាចទទួលយកបានដោយផ្អែកលើមូលដ្ឋានដូចបានលើកឡើងខាងលើដែលជាបញ្ហានីតិវិធី ទើបធ្វើឱ្យការពិនិត្យលើបញ្ហានេះក្លាយជាអាទិភាព។

២៤. ទាក់ទងទៅនឹងការដាក់បណ្ដឹងសាទុក្ខនេះឱ្យបានទាន់ពេល ដែលត្រូវបានលើកឡើង ដោយសហព្រះរាជអាជ្ញា វិធាន ១០៧ នៃវិធានផ្ទៃក្នុងចែងនៅក្នុងផ្នែកពាក់ព័ន្ធដូចខាងក្រោមថា៖

> ១. ក្នុងករណីដែលសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងបើកឱ្យមានបណ្ដឹងសាទុក្ខភ្លាមៗ ដូចមានចែងក្នុងវិធាន ១០៤(៤)(ក) និង(ឃ) បណ្ដឹងសាទុក្ខត្រូវធ្វើឡើងក្នុងរយៈពេល ៣០ ថ្ងៃចាប់ពីថ្ងៃប្រកាសសេចក្ដីសម្រេចឬពីថ្ងៃជូនដំណឹងអំពីសេចក្ដីសម្រេចនោះ។

២៥. តាំងពីដំបូង អង្គជំនុំជម្រះតុលាការកំពូលបានបញ្ជាក់ថា ការដាក់បណ្ដឹងសាទុក្ខភ្លាមៗសម្រាប់គោលបំណងនៃវិធាន ១០៧(១) នៃវិធានផ្ទៃក្នុង ត្រូវបញ្ចប់នៅថ្ងៃដាក់បណ្ដឹងសាទុក្ខដែលបានបំពេញលក្ខខណ្ឌតម្រូវជាផ្លូវការដូចមានចែងក្នុងបទប្បញ្ញត្តិជាធរមាន។ ក្នុងរឿងក្ដីបច្ចុប្បន្ន ម្ចាស់បណ្ដឹងសាទុក្ខ បានដាក់បណ្ដឹងសាទុក្ខនៅចំពោះអង្គជំនុំជម្រះតុលាការកំពូល ដែលជាការរំលោភលើវិធាន ១០៦(២) នៃវិធានផ្ទៃក្នុងដែលចែងថា "បណ្ដឹងសាទុក្ខ និងបណ្ដឹងសាទុក្ខភ្លាមៗត្រូវដាក់ជូនក្រឡាបញ្ជីនៃអង្គជំនុំជម្រះសាលាដំបូង"។ នៅថ្ងៃទី ១១ ខែ តុលា ឆ្នាំ ២០១៦ នោះគឺជាថ្ងៃដែលបណ្ដឹងសាទុក្ខត្រូវបានបញ្ជូនទៅក្រឡាបញ្ជីនៃអង្គជំនុំជម្រះសាលាដំបូង តាមសំណើរបស់ក្រឡាបញ្ជីនៃអង្គជំនុំជម្រះតុលាការកំពូល ដែលបានផុតកំណត់រយៈពេល ៣០ ថ្ងៃដូចមានចែងក្នុងវិធាន ១០៧(១) នៃវិធានផ្ទៃក្នុង។ ប៉ុន្តែអង្គជំនុំជម្រះតុលាការកំពូលពិចារណាឃើញថា កាលៈទេសៈពិសេសបានកំណត់ថា បណ្ដឹងសាទុក្ខនេះអាចត្រូវយកមកពិនិត្យ និងចាត់ការដោយក្រឡាបញ្ជីនៃអង្គជំនុំជម្រះតុលាការកំពូលចាប់ពីថ្ងៃទី ១០ ខែ តុលា ឆ្នាំ ២០១៦ ប៉ុណ្ណោះ[44]។ តាមទម្លាប់ ម្ចាស់ប

[44] ពីថ្ងៃទី ២៩-៣០ ខែ កញ្ញា ឆ្នាំ ២០១៦ គឺមានពេលឈប់សម្រាកសាធារណៈនៅកម្ពុជា។ បន្ទាប់ពីនោះ បរិវេណ អ.វ.ត.ក នៅបន្តបិទរហូតដល់ថ្ងៃទី ៩ ខែ តុលា ឆ្នាំ ២០១៦ ដោយសារទឹកជន់លិចខ្លាំង។

ណ្ដឹងសាទុក្ខទំនងជាត្រូវបានជូនដំណឹងអំពីការដាក់បណ្ដឹងសាទុក្ខនេះដែលកំណត់ត្រឹមថ្ងៃទី ០៣ ខែ តុលា ឆ្នាំ ២០១៦ ឡើយ ដែលនៅពេលនោះ ពួកគាត់នឹងមានឱកាសដើម្បីដាក់បណ្ដឹងសាទុក្ខម្ដងទៀតជូនទៅក្រឡាបញ្ជីនៃអង្គជំនុំជម្រះសាលាដំបូង ក្នុងរយៈពេលកំណត់ដូចមានចែងក្នុងវិធាន ១០៧(១) នៃវិធានផ្ទៃក្នុង ដែលត្រូវបានអានផ្គួបជាមួយវិធាន ៣៩(៣) នៃវិធានផ្ទៃក្នុង។ តាមសំអាងហេតុទាំងនេះ អង្គជំនុំជម្រះតុលាការកំពូលសម្រេចតាមគំនិតផ្ដួចផ្ដើមរបស់ខ្លួនអនុគ្រោះកំហុសនីតិវិធីដែលប៉ះពាល់ដល់ការដាក់បណ្ដឹងសាទុក្ខនេះ ត្រង់ចំណុចដែលបណ្ដឹងសាទុក្ខនេះត្រូវបានទទួលដោយក្រឡាបញ្ជីនៃអង្គជំនុំជម្រះសាលាដំបូង ក្រោយពេលកំណត់ផុតរលត់អនុលោមតាមវិធាន ១០៧(១) នៃវិធានផ្ទៃក្នុង។

២៦. តម្រូវឱ្យមានការសម្រេច ថាតើមានមូលដ្ឋានគាំទ្រអំណះអំណាងរបស់សហព្រះរាជអាជ្ញាដែលថា បណ្ដឹងសាទុក្ខនេះ ធ្វើដាក់មិនទាន់ពេល ដែរ ឬយ៉ាងណា ដោយហេតុថា សេចក្ដីសម្រេចដែលរងការជំទាស់នេះ"ដូចគ្នាបេះបិត"ទៅនឹងសេចក្ដីសម្រេចមុនៗរបស់អង្គជំនុំជម្រះសាលាដំបូង ដែលម្ចាស់បណ្ដឹងសាទុក្ខពុំបានប្ដឹងសាទុក្ខជំទាស់នៅពេលវេលាពាក់ព័ន្ធ[45]។ សហព្រះរាជអាជ្ញាបានចង្អុលបង្ហាញសេចក្ដីសម្រេចលើការជំទាស់ផ្នែកនីតិវិធីដែលបានដាក់នៅខែ មេសា ឆ្នាំ ២០១៤ និងសេចក្ដីសម្រេចលើការសួរតទល់មុខគ្នារបស់សាក្សី ដែលបានចេញនៅខែ មិថុនា ឆ្នាំ ២០១៥។ ម្ចាស់បណ្ដឹងសាទុក្ខបានអះអាងថា បណ្ដឹងសាទុក្ខរបស់ខ្លួន ព្រមទាំងសេចក្ដីសម្រេចដែលរងការជំទាស់នេះ ដែលបានសម្រេចលើសំណើរបស់ពួកគាត់សុំការបញ្ជាក់ ទាក់ទងវិសាលភាពនៃសំណុំរឿង ០០២/០២ (និយាយម្យ៉ាងទៀត *វិសាលភាពនៃសំណុំរឿង*របស់អង្គជំនុំជម្រះសាលាដំបូង)។ ម្ចាស់បណ្ដឹងសាទុក្ខព្យាយាមញែកបញ្ហានេះ ចេញពីបញ្ហាដែលត្រូវបានដោះស្រាយក្នុងសេចក្ដីចំនួន ២ របស់អង្គជំនុំជម្រះសាលដំបូង ដែលត្រូវបានរំលឹកដោយសហព្រះរាជអាជ្ញា ជាសេចក្ដីសម្រេចដែលម្ចាស់បណ្ដឹងសាទុក្ខបានយល់ឃើញថា បានផ្ដោតទៅលើអត្ថិភាពនៃអំពើរំលោភសេពសន្ថវៈជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដាច់ដោយឡែកមួយក្នុងឆ្នាំ ១៩៧៥ ជាជាងទៅលើ *វិសាលភាពនៃសំណុំរឿង*របស់អង្គជំនុំជម្រះសាលាដំបូង ទាក់ទងទៅនឹងការចោទប្រកាន់អំពីការរំលោភសេពសន្ថវៈនៅក្រៅបរិបទនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ[46]។

២៧. អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ឃើញថា សំណើរបស់ម្ចាស់បណ្ដឹងសាទុក្ខត្រូវបានដោះ

[45] ចម្លើយតបរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ១៨។

[46]បណ្ដឹងសាទុក្ខ, កថាខណ្ឌ ៦១។

ស្រាយនៅក្នុងសេចក្តីសម្រេចស្តីពីអញ្ញត្រកម្ម ("សារណារបស់ដើមបណ្តឹងរដ្ឋប្បវេណីឆ្នាំ ២០១១" ) មានទទ្បីករណ៍សំខាន់ៗចំនួនពីរ៖ ការរំលោភសេពសន្ថវៈមានអត្ថិភាពក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិ ជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិក្នុងឆ្នាំ ១៩៧៥[47] និងថា ក្នុងដីកាដំណោះស្រាយ សហចៅក្រមស៊ើបអង្កេតមានកំហុស ដោយបានបដិសេធមិនចោទប្រកាន់ជនជាប់ចោទពីករណីនៃការរំលោភសេពសន្ថវៈដែលបានកើតឡើងនៅក្រៅបរិបទនៃអាពាហ៍ពិពាហ៍ដោយបង្ខំ[48] កំហុសដែលដើមបណ្តឹងសាទុក្ខយល់ឃើញថា តម្រូវឲ្យ"កែប្រែប្រភេទបទល្មើសនៃការចោទប្រកាន់ផ្នែកអង្គហេតុទាំងនោះឡើងវិញ"[49]។ ដោយហេតុថា ដូចដែលម្ចាស់បណ្តឹងសាទុក្ខ និងសហព្រះរាជអាជ្ញាបានយល់ស្រប"*វិសាលភាពនៃសំណុំរឿង* មានអានុភាពជាការកែប្រែប្រភេទបទល្មើស"[50] សំណើសុំឲ្យកែប្រែប្រភេទបទល្មើសមាននៅក្នុងសារណារបស់ដើមបណ្តឹងរដ្ឋប្បវេណីឆ្នាំ ២០១១ ប្រាកដជាត្រូវបានសន្មតថា អង្គជំនុំជម្រះសាលាដំបូង បើទោះបីជាមានការបដិសេធមិនចោទប្រកាន់របស់សហចៅក្រមស៊ើបអង្កេតពីបទរំលោភសេពសន្ថវៈនៅក្រៅបរិបទនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំក៏ដោយ ក៏ពិតជាបានទទួលយកការចោទប្រកាន់ផ្នែកអង្គហេតុទាំងនេះ ដែលម្ចាស់បណ្តឹងសាទុក្ខបានស្នើសុំឲ្យអង្គជំនុំជម្រះសាលាដំបូង ធ្វើការកែប្រែប្រភេទបទល្មើសនៃការចោទប្រកាន់នេះឡើងវិញ។

២៨. ជាការឆ្លើយតប សេចក្តីសម្រេចស្តីពីអញ្ញត្រកម្មបានបញ្ជាក់ថា អង្គជំនុំជម្រះសាលាដំបូងពុំមានសិទ្ធិទទួលយក"សំណើសុំបន្ថែមបទចោទនៃការរំលោភសេពសន្ថវៈ" របស់ម្ចាស់បណ្តឹងសាទុក្ខឡើយ[51]។ ដើម្បីឱ្យស្របជាមួយភាពសមហេតុផលដូចគ្នានេះ អង្គជំនុំជម្រះសាលាដំបូងបានសម្រេចបន្ថែមទៀតថា ខ្លួន"ពុំអាចបន្ថែមអង្គហេតុ ឬបទចោទថ្មីៗពីលើដីកាដំណោះស្រាយដែលត្រូវបានច្រានចោលដោយសហចៅក្រមស៊ើបអង្កេតឡើយ"[52]។ អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ឃើញថា អង្គជំនុំជម្រះសាលាដំបូងពុំបានបដិសេធសំណើសុំកែប្រែប្រភេទបទល្មើស ប៉ុន្តែ

---

[47] សារណា២០១១របស់ដើមបណ្តឹងរដ្ឋប្បវេណី កថាខណ្ឌ ៦-៣១។

[48] សារណា២០១១របស់ដើមបណ្តឹងរដ្ឋប្បវេណី កថាខណ្ឌ ៣២,៤០។

[49] សារណា២០១១របស់ដើមបណ្តឹងរដ្ឋប្បវេណី កថាខណ្ឌ ៤០។ *សូមមើល* សារណា២០១១របស់ដើមបណ្តឹងរដ្ឋប្បវេណី, កថាខណ្ឌ ៤៣, ៤៥(ii)។

[50] បណ្តឹងសាទុក្ខ, កថាខណ្ឌ ៧៦។ *សូមមើលផងដែរ* ចម្លើយតបរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ៣១។

[51] សេចក្តីសម្រេចស្តីពីអញ្ញត្រកម្ម, កថាខណ្ឌ ៣។

[52] សេចក្តីសម្រេចស្តីពីអញ្ញត្រកម្ម, កថាខណ្ឌ ៣។

បានបដិសេធសំណើសុំបន្ថែមបទចោទ។ ប្រការនេះនាំឲ្យអង្គជំនុំជម្រះសាលាដំបូងយល់ឃើញថា ខ្លួនពុំបានទទួលយកការចោទប្រកាន់ផ្នែកអង្គហេតុនៃការរំលោភសេពសន្ថវៈ នៅក្រៅបរិបទនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ និងបានផ្តល់ចម្លើយច្បាស់លាស់ចំពោះបញ្ហា *វិសាលភាពនៃសំណុំរឿង*។ សេចក្តីសង្កេតមួយទៀតដែលចេញមកពីសេចក្តីសម្រេចស្តីពីអញ្ញត្រកម្ម[53] គឺថា ប្រសិនបើម្ចាស់បណ្តឹងសាទុក្ខមានបំណងជំទាស់ទៅនឹងសំអាងហេតុ"ដែលមានកំហុស"[54] នៃដីកាដំណោះស្រាយ មធ្យោបាយដ៏ត្រឹមត្រូវធ្វើដូច្នេះ គឺតាមរយៈបណ្តឹងសាទុក្ខទៅអង្គបុរេជំនុំជម្រះ។

២៩. អង្គជំនុំជម្រះតុលាការកំពូលត្រូវវាយតម្លៃលើបញ្ហា ថាតើបញ្ហាគតិយុត្តិដែលត្រូវបានសម្រេចតាមរយៈសេចក្តីសម្រេចស្តីពីអញ្ញត្រកម្ម និងសេចក្តីសម្រេចដែលរងការជំទាស់នេះ ជាបញ្ហាដូចគ្នាដែរឬយ៉ាងណា។ ក្នុងសេចក្តីសម្រេចស្តីពីអញ្ញត្រកម្ម អង្គជំនុំជម្រះសាលាដំបូងបានផ្តល់សំអាងហេតុពេញលេញទាក់ទងទៅនឹង *វិសាលភាពនៃសំណុំរឿង* ទល់នឹងការចោទប្រកាន់ផ្នែកអង្គហេតុនៃរំលោភសេពសន្ថវៈនៅក្រៅបរិបទនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ។ សេចក្តីសម្រេចដែលរងការជំទាស់នេះ គឺមិនខុសគ្នាឡើយ។ ផ្ទុយទៅនឹងការលើកឡើងរបស់ម្ចាស់បណ្តឹងសាទុក្ខ[55] សេចក្តីសម្រេចដែលរងការជំទាស់នេះ ពាក់ព័ន្ធនឹងបញ្ហា"វិសាលភាពនៃបទចោទអំពីការរំលោភសេពសន្ថវៈទៅលើជនជាប់ចោទក្នុងសំណុំរឿង ០០២/០២"[56] តាមរយៈការផ្តល់សេចក្តីសង្ខេបដែលមានសំអាងហេតុពេញលេញនៃដីកាសម្រេច ឬសេចក្តីសម្រេចនានាដែលចេញដោយសហចៅក្រមស៊ើបអង្កេត អង្គបុរេជំនុំជម្រះ និងអង្គជំនុំជម្រះសាលាដំបូងស្តីពីបញ្ហានេះ[57]។ បើទោះបីជា សេចក្តីសម្រេចដែលរងការជំទាស់ បានពង្រីកបន្ថែមបន្តិចបន្តួចអំពីសំអាងហេតុដែលមានរួចហើយក្នុងសេចក្តីសម្រេចមុនៗរបស់ខ្លួនក៏ដោយ[58] ក៏សេចក្តីសម្រេចនេះបានបញ្ឈប់បន្ថែមសំអាងហេតុសំខាន់ៗ *ថ្មីៗ*ទៀតហើយ។ ប៉ុន្តែ អង្គជំនុំជម្រះសាលាដំបូងគ្រាន់តែបញ្ជាក់ជាថ្មីអំពីជំហជាហូរហែររបស់ខ្លួនថា ការទទួលយកសំណើរបស់ម្ចាស់បណ្តឹងសាទុក្ខ គឺស្មើទៅនឹងការបន្ថែមអង្គហេតុ ឬ

[53] សេចក្តីសម្រេចស្តីពីអញ្ញត្រកម្ម, កថាខណ្ឌ ៣ ("អង្គហេតុ ឬការចោទ [...] ដែលត្រូវបានច្រានចោលដោយសហចៅក្រមស៊ើបអង្កេត, *សេចក្តីសម្រេចដែលពុំត្រូវបានរំខានដោយអង្គបុរេជំនុំជម្រះ*" សេចក្តីបញ្ជាក់បន្ថែម)។

[54] សារណា២០១១របស់ដើមបណ្តឹងរដ្ឋប្បវេណី កថាខណ្ឌ ៤០។

[55] បណ្តឹងសាទុក្ខ, កថាខណ្ឌ ៧៣-៧៥។

[56] សេចក្តីសម្រេចដែលរងការជំទាស់ កថាខណ្ឌ ២០។

[57] សេចក្តីសម្រេចដែលរងការជំទាស់ កថាខណ្ឌ ១២-១៤, ១៦-១៨។

[58] សេចក្តីសម្រេចដែលរងការជំទាស់ កថាខណ្ឌ ១៥, ១៩។

បទចោទថ្មីៗទៅលើការចោទប្រកាន់នោះ ដែលជាការរំលោភលើវិធាន ៩៨(២) នៃវិធានផ្ទៃក្នុង។ ជារួម សេចក្តីសម្រេចដែលរងការជំទាស់ត្រូវបានកំហិតត្រឹមការបញ្ជាក់ជាថ្មីអំពីសំអាងហេតុដដែល ដែលបានលើកឡើងរួចហើយក្នុងសេចក្តីសម្រេចស្តីពីអញ្ញត្រកម្មកាលពីពីរឆ្នាំមុន។ ប្រសិនបើម្ចាស់បណ្តឹងសាទុក្ខ មានបំណងជំទាស់នៅក្នុងបណ្តឹងសាទុក្ខនូវការសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងទាក់ទងទៅនឹង*វិសាលភាពនៃសំណុំរឿង* ពាក់ព័ន្ធការរំលោភសេពសន្ថវៈនៅក្រៅបរិបទនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ ពួកគាត់គួរបានធ្វើដូច្នោះកាលពីពេលនោះ។ ហេតុដូច្នេះ បណ្តឹងសាទុក្ខ បច្ចុប្បន្នរបស់ពួកគាត់ត្រូវបានចាត់ទុកថា ជាបណ្តឹងយឺតពេល តាមវិធាន ១០៧(១) នៃវិធានផ្ទៃក្នុង។

៣០. ផ្អែកលើការលើកឡើងខាងលើ អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា ពុំមានភាពចាំបាច់ក្នុងការពិចារណាទៅលើបញ្ហាសេសសល់បន្ថែមទៀតឡើយ។

## IV. **ផ្នែកសម្រេចសេចក្តី**

៣១. យោងតាមសំអាងហេតុខាងលើ អង្គជំនុំជម្រះតុលាការកំពូលសម្រេចៈ

**បដិសេធ**បណ្តឹងសាទុក្ខនេះមិនអាចទទួលយកបាន អនុលោមតាមវិធាន ១០៧(១) នៃវិធានផ្ទៃក្នុង។

ភ្នំពេញ ថ្ងៃទី ១២ ខែ មករា ឆ្នាំ ២០១៧

**ប្រធានអង្គជំនុំជម្រះតុលាការកំពូល**

**គង់ ស្រីម**